ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# «ការប្រារព្ធទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស»
# លើកទី០៨ ឆ្នាំ២០២៤ ក្រោមប្រធានបទ៖
# «ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល»

រាជធានីភ្នំពេញ៖ «**ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤**» ក្រោមប្រធានបទ៖ «**ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល**» ត្រូវបានប្រារព្ធធ្វើឡើងនៅមជ្ឈមណ្ឌលសន្និបាត **និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ** រាជធានីភ្នំពេញ នៅព្រឹកថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ត្រូវនឹងថ្ងៃទី២០ខែសីហា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ សមាជិកព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាល អង្គទូតនានាដែលមាននិវេសនដ្ឋាននៅកម្ពុជា មេដឹកនាំសាសនា និងសាសនិក នៃនិកាយសាសនាធំៗ ក្រុមប្រឹក្សាអភិបាលរាជធានី-ខេត្ត ខណ្ឌ សង្កាត់ មន្ត្រីរាជការ យុវជន យុវនារី កងកម្លាំងគ្រប់ប្រភេទ និងអង្គការដៃគូជាតិ អន្តរជាតិ មានចំនួនសរុបប្រមាណ **២២៥០ អង្គ/នាក់ បានចូលរួមយ៉ាងកុះករ**។ គោលបំណងសំខាន់ៗនៃការប្រារព្ធទិវាជាតិអន្តរសាសនាលើកនេះគឺដើម្បី៖

*១-បញ្ជាក់ពីគោលជំហរ និងការប្តេជ្ញាចិត្តដ៏មុតមាំ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមយុទ្ធសាស្ត្រគ្រោងទុក ដោយមានការចូលរួមពីវិស័យសាសនា។*

*២-បង្ហាញអំពីសុខដុមនីយកម្មនៃសាសនានៅកម្ពុជា ដែលមូលមតិគ្នាចូលរួមប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីពង្រឹងសុខសន្តិភាព និងសុវត្ថិភាពមនុស្សពីអំពើជួញដូរមនុស្ស ។*

*៣-បង្ហាញអំពីសារសំខាន់នៃតួនាទីរបស់សាសនាក្នុងសង្គម និងសក្តានុពលក្នុងការអប់រំសីលធម៌ប្រកបដោយភាពទន់ភ្លន់ របស់សាសនា ជាពិសេស ព្រះពុទ្ធសាសនា ឥស្លាមសាសនា និងគ្រីស្តសាសនា ដើម្បីបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។*

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** អនុប្រធានអចិន្ត្រៃយ៍ គជបជ បានធ្វើសេចក្តីរាយការណ៍អំពីសារសំខាន់ និងសារតានៃការប្រារព្ធ «ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ២០សីហា» នេះ ដោយត្រូវបានចាប់ផ្តើមឡើង លើកទី១ នៅឆ្នាំ២០១៧ ហើយត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភា អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសជាផ្លូវការ ក្នុងពិធីវេទិការអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស នៅឆ្នាំ២០២២ កំណត់យកថ្ងៃទី២០ខែសីហា **ជា «ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស»** ។ លោកជំទាវ បានបញ្ជាក់ថា ៖ បច្ចុប្បន្ន ពិភពលោកមានការរីកចម្រើនយ៉ាងលឿនមហិមា នៃបច្ចេកវិទ្យា

វិទ្យាសាស្ត្រព័ត៌មាន ដែលហៅថា ឌីជីថល ដែលបមម្រើឱ្យការអភិវឌ្ឍន៍គ្រប់វិស័យ និងសម្រាប់ប្រើជាមធ្យោបាយទំនាក់ទំនង គ្រប់គ្រង បញ្ហា ទាំងក្នុងវិស័យរដ្ឋ ទាំងវិស័យឯកជន តែក៏រងនូវផលប៉ះពាល់ ទាំងវិជ្ជមាន ទាំងអវិជ្ជមាន ដ៏ធំធេង ព្រោះបច្ចេកវិទ្យានេះ ក៏ត្រូវបានពួកឧក្រិដ្ឋជនប្រើប្រាស់ដើម្បីធ្វើសកម្មភាពឧក្រិដ្ឋកាន់តែងាយស្រួល និងរីករាលដាលធាប់រហ័សហួសពីការស្មានផងដែរ។ មានន័យថាៈ «**ភាពវ័យឆ្លាតនៃវិទ្យាសាស្ត្រតែម្យ៉ាង មិនអាចនាំមកនូវសេចក្តីសុខដល់មនុស្សជាតិ និងពិភពលោកបានទេ បើមនុស្សអ្នកបង្កើត និងអ្នកប្រើប្រាស់វិទ្យាសាស្ត្រ គ្មានសីលធម៌ គ្មានគុណធម៌ និងគ្មានចេតនាធ្វើឱ្យមានសេចក្តីសុខ**»។

ក្នុងឆ្នាំ២០២៤នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបង្កើនកិច្ចសហការ ជាមួយវិស័យសាសនា ក្រសួងស្ថាប័នជាសមាជិក គ.ជ.ប.ជ មានជាអាទិ៍ ក្រសួងធម្មការនិងសាសនា ក្រសួងព័ត៌មាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំយុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងការបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងសាសនាទាំងបី អង្គការមិនមែនរដ្ឋាភិបាល សហគ្រិនស្ត្រី សមាគមសិល្បករកម្ពុជា ជាតំណាងវិស័យឯកជន ដោយបានមូលមតិគ្នាជ្រើសយកប្រធានបទ « ការអប់រំសីលធ៌មតាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងសម័យឌីជីថល» សម្រាប់ទិវាជាតិអន្តរសាសនា ប្រចាំឆ្នាំ២០២៤ នេះ ។

ក្នុងឱកាសនោះផងដែរ **សម្តេចព្រះមហាអរិយវង្ស បណ្ឌិត យ៉ន សេងយៀត** ព្រះសាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងជាព្រះអនុប្រធានលេខាធិការដ្ឋានគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានមានព្រះថេរដីការបញ្ជាក់ពីភាពសំខាន់នៃការចូលរួមចំណែកពីវិស័យសាសនាទាំងអស់ ក្នុងការអប់រំណែនាំដល់បរិស័ទនៅក្នុងសាសនាខ្លួន ឱ្យយល់ដឹងពីអំពើជួញដូរមនុស្ស ដើម្បីចូលរួមរាយការណ៍ និងបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដោយអំពាវនាវទៅមេដឹកនាំនិងសាសនិកសាសនាទាំងអស់នៅកម្ពុជា ថាៈ

១-អ្នកដឹកនាំសាសនាត្រូវចូលរួមអប់រំបរិស័ទរបស់ខ្លួន ឱ្យយល់ដឹង អំពីអំពើជួញដូរមនុស្ស និងផលប៉ះពាល់ដែលកើតឡើងដោយសារអំពើជួញដូរមនុស្ស ដោយគប្បី «អប់រំឱ្យមនុស្សចេះរស់នៅដោយល្អឱ្យបានច្រើននៅលើភពផែនដីនេះ ជាជាងបង្រៀនឱ្យមនុស្សឡើងឋានសួគ៌»។

២-ការជួញដូរមនុស្សអាចកើតឡើងលើបុគ្គលគ្រប់រូប មិនប្រកាន់អ្នកមាន ឬគ្មានជំនឿ សាសនា នោះឡើយ ដូច្នេះយើងត្រូវចូលរួមជួយទាំងអស់គ្នា ព្រោះ «បុគ្គលណាក៏អាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរ»។

៣-យើងត្រូវសកម្ម មិនត្រូវស្ងប់ស្ងៀម មិនត្រូវបិទភ្នែកនៅពេលដឹងថាមានឧក្រិដ្ឋកម្មជួញដូរមនុស្សកើតឡើងនោះទេ គឺយើងត្រូវរាយការណ៍ដល់អាជ្ញាធរពាក់ព័ន្ធពីអំពើជួញដូរមនុស្សដែលកើតមាន ។

៤-យើងត្រូវចូលរួមការពារ បង្រៀន និងលើកទឹកចិត្តដល់បរិស័ទរបស់ខ្លួនក្នុងការផ្សព្វផ្សាយព័ត៌មានបន្តដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

៥-ត្រូវសហការចូលរួមជាមួយរាជរដ្ឋាភិបាលដោយស្មគ្រ័ចិត្ត ដោយសារផលប៉ះពាល់ដល់បរិស័ទក្នុងសាសនា ក៏ជះឥទ្ធិពលប៉ះពាល់ដល់សាសនាទាំងមូលផងដែរ។

៦-វិស័យសាសនាគួរដើរតួរជាគម្រូក្នុងការចូលរួមយ៉ាងសកម្មក្នុងការប្រៀនប្រដៅ ផ្តល់ឱវាទ ណែនាំដើម្បី បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

៧-តួនាទីរបស់បព្វជិតសាសនាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការចូលរួមជួយគាំទ្រ ផ្តល់ភាពសង្គ្រោះដល់ជនរងគ្រោះតាមរយៈសាសនារបស់ខ្លួនឱ្យបានវិលត្រឡប់ចូលរួមក្នុងសកម្មភាព និងសហគមន៍សាសនារបស់ខ្លួនឡើងវិញ ប្រកបដោយក្តីមេត្តា និងដោយគ្មានការរើសអើង។

កិច្ចសូត្រព្រះធម៌ ដើម្បីបួងសួង អធិដ្ឋានសុំសេចក្តីសុខ តាមសាសនានីមួយៗ ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ។ បន្ទាប់មក **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃ**ព្រះរាជាណាចក្រកម្ពុជា** បានថ្លែងកោតសរសើរដល់ អគ្គលេខាធិការដ្ឋាន គជបជ ដែលដឹកនាំដោយ លោកជំទាវ **ជូ ប៊ុនអេង**

អនុប្រធានអចិន្ត្រៃយ៍ ដែលមានយុទ្ធសាស្ត្រ និងផែនការច្បាស់លាស់ និងបានបន្តប្រារព្ធទិវាជាតិអន្តរសាសនានេះយ៉ាងខ្ជាប់ខ្ជួន ដើម្បីបន្តជំរុញឱ្យមានការចូលរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធទាំងជាពិសេស ពីវិស័យសាសនា ក្នុងការបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាការប្តេជ្ញាចិត្តរាជរដ្ឋាភិបាល ។ **ឯកឧត្តមអភិសន្តិបណ្ឌិត** បានបញ្ជាក់បន្ថែមថា ការរីកចម្រើនដ៏ឆាប់រហ័ស នៃបច្ចេកវិទ្យា វិទ្យាសាស្ត្រ ក្តួបផ្សំនឹងសមត្ថភាព ជំនាញរបស់អ្នកប្រើប្រាស់ ដែលកើនឡើងយ៉ាងខ្លាំងផងដែរ បានធ្វើឱ្យបទល្មើសកាន់តែស្មុគ្រស្មាញ និងបង្កផលវិបាកជាអវិជ្ជមានក្នុងសង្គម ។ ក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ មិនបានព្រងើយកន្តើយឡើយ ហើយតែងតែអំពាវនាវ ឱ្យមានកិច្ចសហការកាន់តែរឹងមាំពីបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ ទាំងក្នុងតំបន់ និងជាអន្តរជាតិ ឱ្យរួមគ្នាដោះស្រាយ។ រាជរដ្ឋាភិបាល បានដាក់ចេញ និងបន្តអនុវត្ត **«ផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់»** ដោយប្រុងប្រយ័ត្ន និងដោយគ្មានការធ្វេសប្រហែស ។ គោលការណ៍សំខាន់បួនយ៉ាងនៃផែនការប្រតិបត្តិការនេះគឺ (១) សង្គ្រោះជនរងគ្រោះឱ្យបានទាន់ពេលវេលា (២) ស៊ើបអង្កេតរកជនប្រព្រឹត្តបទល្មើស និងបក្សពួក និងស្រាវជ្រាវរកមេខ្លោង ដើម្បីផ្តន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែង (៣) ត្រួតពិនិត្យប្រមូលកស្តុតាង ដើម្បីបិទអាជីវកម្មខុសច្បាប់ពាក់ព័ន្ធ និង(៤) ពន្លាតការស៊ើបអង្កេតរកសកម្មភាពបទល្មើសសម្អាតប្រាក់ របស់ជនល្មើស។

ជាទីបញ្ចប់ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ក្នុងនាមប្រមុខរាជរដ្ឋាភិបាល បានផ្តល់នូវអនុសាសន៍ សម្រាប់បន្តអនុវត្តក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដូចខាងក្រោម៖

*១-បន្តការអប់រំសីលធម៌តាមគន្លងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃការរស់នៅប្រកបដោយសីលធម៌ និងគុណធម៌ អាចឱ្យមនុស្សភ្ញាក់រលឹក និងទទួលយកការយល់ដឹងអំពីបទល្មើសជួញដូរមនុស្ស និងផលប៉ះពាល់ដើម្បីបង្ការទប់ស្កាត់ ធ្វើឱ្យសេចក្តីសុខ សន្តិភាពផ្លូវកាយ ផ្លូវចិត្ត និងមិនប្រព្រឹត្តទង្វើទុច្ចរិត ឬបទល្មើសផ្សេងៗដែលនាំទុក្ខដល់ខ្លួន។*

*២-អំពាវនាវឱ្យមានកិច្ចសហការកាន់តែល្អប្រសើររវាង ក្រសួងធម្មការ និងសាសនា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ជាពិសេស មេដឹកនាំសាសនាធំៗទាំងបី ក្រោមការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលដឹកនាំដោយលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ដើម្បីរៀបចំផែនការសកម្មភាពបន្ត ឱ្យបានជាក់លាក់ ងាយស្រួលដល់ការធ្វើសកម្មភាពព្រមៗគ្នា និងមានទិន្នន័យ ជាលទ្ធផល សម្រាប់ការរៀបចំទិវាជាតិអន្តរសាសនាលើកក្រោយទៀត ។*

*៣-សូមអំពាវនាវ ដល់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ នៅថ្នាក់ក្រោមជាតិ ជួយបង្កលក្ខណៈនិងចូលរួមក្នុងសកម្មភាពអប់រំតាមបែបសាសនា ក្នុងគោលដៅបង្កើតឱ្យមានសុវត្ថិភាពនៅតាមបណ្តា ភូមិ ឃុំ សង្កាត់ទូទាំងប្រទេស ដែលនឹងជួយពង្រឹងដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ ក្នុងសង្គម ។*

កម្មវិធីទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤ ក្រោមប្រធានបទ «ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងសម័យឌីជីថល» បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងអធឹកអធម្មក្រៃលែង ៕